*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន
# បុណ្យរំឭកខួប១៣ឆ្នាំ នៃមរណៈភាពលោក ឈុត វុទ្ធី

នៅរសៀល ថ្ងៃសៅរ៍ ទី២៦ ខែមេសា ឆ្នាំ២០២៥ ខាងមុខនេះ អង្គការមិនមែនរដ្ឋាភិបាល សមាគម និងសហគមន៍ បានសហការប្រារព្ធពិធីបង្សុកូល និងរំឭកខួប១៣ឆ្នាំ នៃមរណៈភាពរបស់លោក **ឈុត វុទ្ធី** វីរជនការពារព្រៃឈើ។

ការប្រារព្ធរំឭកខួបនេះ ធ្វើឡើងក្នុងគោលបំណង៖ ១). បង្សុកូល និងរំឭកពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ គុណតម្លៃនៃសកម្មជនសិទ្ធិមនុស្ស និងបរិស្ថានដែលត្រូវបានបាញ់សម្លាប់នៅកម្ពុជា ក្នុងបុព្វហេតុចូលរួមថែរក្សា និងការពារធនធានធម្មជាតិ ២). រំឭកដល់ភាពសកម្មនិយមរបស់យុវជន និងទាមទារយុត្តិធម៌ជូនជនរងគ្រោះដែលត្រូវបានសម្លាប់ក្រៅប្រព័ន្ធតុលាការ។

ការប្រារព្ធកម្មវិធីពេញមួយរសៀលនេះ នឹងមានកម្មវិធីសំខាន់ៗដូចជា សូត្រមន្ត បង្សុកកូលឧទ្ទិសកុសលជូនជនរងគ្រោះ វេទិកាថ្លែងសារពីតំណាងអង្គការសង្គមស៊ីវិល និង ការបង្ហោះសារយុទ្ធនាការទាមទារយុត្តិធម៌។ លើសពីនេះទៅទៀត នៅក្នុងកម្មវិធីនេះ ក៏មានការធ្វើសេចក្តីថ្លែងការណ៍រួមរបស់យុវជនដែលបង្ហាញអំពីការព្រួយបារម្ភរបស់យុវជនចំពោះស្ថានភាពសិទ្ធិមនុស្ស បរិស្ថាន និងធនធានធម្មជាតិ និងអំពាវនាវឱ្យមានការធានាពីការគាំពារភាពសកម្មនិយមរបស់យុវជន ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**<u>កម្មវិធីលម្អិត</u>**

**កម្មវិធី** : បុណ្យរំឭក ខួប១៣ឆ្នាំ នៃមរណៈភាព លោក ឈុត វុទ្ធី

**កាលបរិច្ឆេទ** : ថ្ងៃសៅរ៍ ទី២៦ ខែមេសា ឆ្នាំ២០២៥ ចាប់ពីម៉ោង ២:០០ រសៀល ដល់ម៉ោង ៤:៣០ ល្ងាច

**ទីកន្លែង** : សហភាពផ្ទះសាមគ្គី អាសយដ្ឋាន ផ្ទះលេខ ៣៥ ផ្លូវ១០១៣ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកសារព័ត៌មានជាតិ និងអន្តរជាតិមេត្តាជ្រាប និងចូលរួមយកព័ត៌មាននៅក្នុងកម្មវិធីនេះ៕

<u>សម្រាប់ព័ត៌មានលំអិតសូមទំនាក់ទំនង៖</u>

១. លោក **ម៉ី ចាន់ដារ៉ា** លេខទូរស័ព្ទ ០៨១ ៣៣២ ៣៤០

២. លោក **សាន់ ម៉ាឡា** លេខទូរស័ព្ទ ០១៥ ៩៩៨ ៥៥៥